**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៦៧ សហវ.ប្រក

ភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០០៦

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអរ កម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/ ១២៩៩/១៥ ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០២
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០៤
- បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសអន្តរក្រសួងលេខ ០០២សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី

**សម្រេច**

**ប្រការ១**: បង្កើតក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ដែលមានសមាជិក ដូចរាយនាមខាងក្រោម:

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម អូន ពន្ធមុនីរ័ត្ន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២ | ឯកឧត្តម ជុំ គឹមឡេង | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម ទិន ឃន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានធនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តម អ៊ឹន ចន្ថា | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥. | ឯកឧត្តម អ៊ឹក សុខុន | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៦. | ឯកឧត្តម រ័ត្ន សារិន | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៧. | ឯកឧត្តម តែ គុយសៀង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |
| ៨. | ឯកឧត្តម ជា សឿង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. | ឯកឧត្តម គុំ សារ៉ុន | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១០. | ឯកឧត្តម ជួប សំអាត | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១. | ឯកឧត្តម ឡៅ ហ៊ីម | អគ្គនាយកបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២. | លោកស្រី យក់ សម្បត្តិ | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |
| ១៣. | លោក សុខ សារាឧត្តម | ប្រធាននាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤. | លោក នួច ឡេង | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥. | លោក ឆាយ ទុជ | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២**: លេខាធិការដ្ឋានរបស់ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ត្រូវបានបង្កើត និង មានសមាជិក ដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. | លោក ហ៊ីង សុវណ្ណ | អនុប្រធានទី១ធនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោក ឡូ វាសនាគីរី | ប្រធាននាយកដ្ឋានផែនការ-ព័ត៌មានក្រសួងសុខាភិបាល | សមាជិក |
| ៣. | លោក ជា គឹមឡុង | ប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |

៤. លោក លី សន្តិ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៥. លោក ឡុង ម៉ុនលី ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

៦. លោក សាម សាយ ប្រធាននាយកដ្ឋានផ្គត់ផ្គង់-ហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៧. លោក នូវ តុល្លី ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៨. លោក ស្វាយ ទិចិត្រ្ត ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរដ្ឋ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៩. លោក អៀង ស៊ុនលី អនុប្រធានទី១ នាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០. លោក ឈឹម សារ៉េត អនុប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១. លោក ទន្សុ វ៉ែងទុល្ស អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១២. លោកស្រី មាស សុខុម អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ ក្រសួងកិច្ចការនារី សមាជិក

១៣. លោក ស្រី ទុង ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងសុខាភិបាល សមាជិក

១៤.លោក មុី ចន្ទ័ម្ភុរ៉ា ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥. លោក ហ៊ុយ រ៉ាឌី ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៦. លោក ចិន ឬទ្ធិ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៧. លោក សេង ចំរើន ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៨. លោក ជូ ម៉ារុំ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៩. លោក ទង់ ពេជ្រ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងកិច្ចការនារី សមាជិក

២០.លោកស្រី នាយ អ៊ឹម មន្ត្រីរៀបចំកម្មវិធីសកម្មភាពជាអាទិភាព PAP ក្រសួងកិច្ចការនារី សមាជិក

**ប្រការ៣:** ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ត្រូវទទួលបន្ទុកៈ

- កំណត់អោយបាននំពីមូលហេតុដែលនាំអោយការបើកផ្តល់សាច់ប្រាក់មានភាពយឺតយ៉ាវ សំរាប់ក្រសួងអាទិភាព ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកែលំអអោយកាន់តែប្រសើរឡើង
- ពិនិត្យ និងតាមដានការអនុវត្តន៍ថវិកាឆ្នាំ ជាពិសេសជំពូក ១៣ និង ជំពូក១១
- រៀបចំផែនការសកម្មភាពរយៈពេលខ្លីស្តីពីការបង្កើនសន្ទុះនៃការបើកផ្តល់សាច់ប្រាក់ ដោយផ្អែកតាមការសំរេចចិត្តនៃគោលនយោបាយអភិវឌ្ឍន៍វិស័យសង្គម ។
- កំណត់អោយបាននូវការលំបាកនានា និងពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព (PAP) របស់សាមីក្រសួង
- រៀបចំផែនការលំអិតដើម្បីកែលំអប្រពន្ធ័កម្មវិធីសកម្មភាពជាអាទិភាព (PAP) និង ពិនិត្យពិចារណាពីតំរូវការផ្នែកច្បាប់ដែលអាចអនុញ្ញាតដល់ការកែលំអកម្មវិធីសកម្មភាពជាអាទិភាពអោយទៅជាការគ្រប់គ្រងថវិកាតាមកម្មវិធី (Program Based Budgeting)

**ប្រការ៤:**

- លេខាធិការដ្ឋានមានសិទ្ធិអញ្ជើញជំនាញការបរទេសពាក់ព័ន្ធចូលរួមតាមការចាំបាច់ និង មានភារកិច្ចរៀបចំលិខិតអញ្ជើញចូលរួមប្រជុំដល់គ្រប់សមាជិកនៃក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់ និងរៀបចំខ្លឹមសាររបៀបវារៈ កំណត់ហេតុ និងបញ្ជីវត្តមានអង្គប្រជុំ (អាចធ្វើឡើងជាភាសាអង់គ្លេសផងដែរ ) ជាពិសេស របាយការណ៍សង្ខេបស្តីពីស្ថានភាពបើកផ្តល់សាច់ប្រាក់របស់ក្រសួងស្ថាប័ននានា ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព ជូនដៃគូអ្នកផ្តល់ជំនួយដែលពាក់ព័ន្ធនានា ។
- សមាជិកក្រុមការងារអាចអញ្ជើញមន្ត្រីជំនាញរបស់ខ្លួនអមជាមួយ ក្នុងកិច្ចដំណើរការប្រជុំ ។

**ប្រការ៥:** យោងតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាណត្តិរបស់ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់ មានរយៈពេល មិនតិចជាង ២ ឆ្នាំ។

**ប្រការ៦:** ប្រកាសអន្តរក្រសួងលេខ ០០២ សហវ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវនិរាករណ៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៧:** អគ្គលេខាធិការ អគ្គនាយក ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ និង ប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

លី_ឡាយស្រេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត កុល ផេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និង សំណង់

អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត_សុខុម

រដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ

ជ័ន្ទ សារុន

រដ្ឋមន្ត្រី
ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ញ៉េប ប៊ុនជិន

រដ្ឋមន្ត្រី
ក្រសួងកិច្ចការនារី

អ៊ឹង កន្ថាផាវី

ចំលងជូន

- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសុខាភិបាល
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអភិវឌ្ឍន៍ជនបទ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងកិច្ចការនារី
- ដូចប្រការ១ និងប្រការ២
- ឯកសារ និង កាលប្បវត្តិ